**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តរតនគិរី**
**ក្រុមលទ្ធកម្ម**
លេខ : ០៤/១៧

 បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការងារជួសជុលអគារស្នាក់នៅសំរាប់មន្ត្រីរាជការ ទំហំ ១៦២ម៉ែត្រការ៉េx២ជាន់=៣២៤ម៉ែត្រការ៉េ (ជំហានទី១ ឆ្នាំ២០១៧) ជូនមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តរតនគិរី

មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តរតនគិរី សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស(គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តរតនគិរី នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការងារជួសជុលអគារស្នាក់នៅសំរាប់មន្ត្រីរាជការ ទំហំ ១៦២ម៉ែត្រការ៉េx២ជាន់=៣២៤ម៉ែត្រការ៉េ (ជំហានទី១ ឆ្នាំ២០១៧) ជូនមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តរតនគិរី ។

មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តរតនគិរី បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅក្រុមលទ្ធកម្មមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តរតនគិរី ដែលមានអាសយដ្ឋាន ភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ចាប់ពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០១២ ៧៩១ ៣០៧ , ០១២ ៥៧៧ ៤៨៧ )។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនក្រុមលទ្ធកម្មមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តរតនគិរី យ៉ាងយូរបំផុតត្រឹមថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ១៤:៣០នាទី។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តរតនគិរី តាមអាសយដ្ឋានខាងលើ វេលាម៉ោង១៤:៣០ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០១៧ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅខេត្តរតនគិរី ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៧
**ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តរតនគិរី**
**និងជាប្រធានក្រុមលទ្ធកម្ម**

ចម្លងជូន ៖
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ

ញាន និត្យបិណ្ឌា